CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២១ ខែមីនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# មជ្ឈមណ្ឌលការងារនៅឡុងប៊ិចនៅតែបើកចំហ

*សេវាកម្មដែលមានសំរាប់អ្នកដែលរងផលប៉ះពាល់ដោយគ្រោះអាសន្ន COVID-19*

ទីក្រុងឡុងប៊ិច,រដ្ឋកាលីហ្វ័រញ៉ា - មជ្ឈមណ្ឌលការងារ The WorkPlace (ដែលមានទីតាំងនៅ 4811 Airport, Plaza Dr. St, 120) នឹងនៅតែបើកចំហដើម្បីជួយដល់ក្រុមគ្រួសារឡុងប៊ិច អ្នកធ្វើការ និងអាជីវកម្មខ្នាតតូចដែលរងផលប៉ះពាល់ពីការផ្ទុះឡើងនៃជម្ងឺ COVID-19។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "យើងដឹងថាភាពអាសន្ននៃសុខភាពបច្ចុប្បន្នកំពុងជះឥទ្ធិពលអវិជ្ជមានដល់កម្មកររាប់ពាន់នាក់និងអាជីវកម្មរាប់រយនៅឡុងប៊ិច។ ការបន្តបើកមជ្ឈមណ្ឌលការងាររបស់យើងដើម្បីជួយដល់និយោជិក កម្មករ និងគ្រួសាររបស់ពួកគេក្នុងគ្រាអាសន្នសេដ្ឋកិច្ចនេះជួយដោះស្រាយបញ្ហាប្រឈមជាច្រើន។"

គ្រប់គ្រងដោយបណ្តាញច្នៃប្រឌិតកម្លាំងពលកម្មប៉ាស៊ីហ្វិក (Pacific Gateway Workforce Innovation Network) មជ្ឈមណ្ឌលការងារ The WorkPlace ផ្តល់សេវាកម្មជំនួយដល់អ្នកធ្វើការក្នុងការស្វែងរកព័ត៌មានអំពីដំណឹងជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាលវិជ្ជាជីវៈ អត្ថប្រយោជន៍ធានារ៉ាប់រងសម្រាប់អ្នកដែលគ្មានការងារធ្វើ និងឱកាសការងារបន្ថែមទៀតនៅសហគមន៍ឡុងប៊ិច Signal Hill និងសហគមន៍កំពង់ផែឡូសអាន់ជីលេស។

សេវាកម្មនៅមជ្ឈមណ្ឌលការងារ The WorkPlace រួមមាន៖

- ជំនួយការស្វែងរកការងារនឹងការភ្ជាប់ទៅនឹងនិយោជិកដែលកំពុងស្វែងរកបុគ្គលិកដើម្បីជួល។
- ការផ្តល់ប្រឹក្សានិងការបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីជួយបុគ្គលបង្កើតផែនការរយៈពេលវែងនិងភ្ជាប់ទៅនឹងវិស័យសេដ្ឋកិច្ចដែលកំពុងរីកចម្រើន។
- ព័ត៌មានអំពីកម្មវិធីពិសេសរបស់រដ្ឋ តំបន់ និងក្រុងសម្រាប់អ្នកធ្វើការដែលប្រឈមនឹងការបញ្ឈប់ការងារនិងការកាត់បន្ថយនៃក្រុមហ៊ុន។

វគ្គផ្តល់ព័ត៌មាននឹងមានចាប់ផ្តើមពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រពីម៉ោង ៩:00 ព្រឹកដល់ម៉ោង ១១:00 ព្រឹក។ ស្របតាមពិធីសារផ្សេងៗនៃការរក្សាចម្ងាយរាងកាយពីគ្នាដែលទាក់ទងនឹងជម្ងឺ COVID-19 វគ្គណែនាំនឹងត្រូវកំណត់ចំពោះបុគ្គល ៩ នាក់តែប៉ុណ្ណោះហើយការប្រឹក្សាយោបល់ដោយមួយទល់មួយនឹងត្រូវធ្វើតាមទូរស័ព្ទ។ ធនធាននិងព័ត៌មានថ្មីៗទាំងនេះនឹងត្រូវបង្ហាញនៅម៉ោង ២:00 រសៀលចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រតាមការផ្សាយបន្តផ្ទាល់ពីប៉ុស្តិ៍របស់ Pacific Gateway នៅក្នុងបណ្តាញ Instagram នៅ @pacgateway.

ព័ត៌មានអំពីប្រាក់កម្ចីសម្រាប់អាជីវកម្មខ្នាតតូច ការប្រឹក្សាសម្រាប់អាជីវកម្ម និងកម្មវិធីផ្សេងទៀតអាចរកបាននៅ www.longbeach.gov/economicdevelopment/covid-19-business-support/.

អាជីវកម្មដែលចង់ដាក់ពាក្យសុំទៅកម្មវិធីប្រាក់កម្ចីរបស់រដ្ឋសហព័ន្ធនិងទីក្រុង កម្មវិធីការងារ WorkShare និងសេវាកម្មគាំទ្រផ្សេងទៀតអាចទូរស័ព្ទមកលេខទូរស័ព្ទទំនាក់ទំនងសម្រាប់អាជីវកម្មរបស់មន្ទីរអភិវឌ្ឍន៍សេដ្ឋកិច្ចនៃទីក្រុងតាមលេខ 562-570-4BIZ (4249) ឬចូលទៅកាន់គេហទំព័រ www.longbeach.gov/economicdevelopment/covid-19-business-support/។

ព័ត៌មានបន្ថែមអំពីមជ្ឈមណ្ឌលការងារ The WorkPlace មាននៅគេហទំព័រ www.pacific-gateway.org.

ទីក្រុងឡុងប៊ិចលើកទឹកចិត្តឱ្យប្រជាជនទាំងអស់ចូលទៅកាន់គេហទំព័រ www.longbeach.gov/COVID19 ដើម្បីទទួលបានព័ត៌មានថ្មីៗទាក់ទងនឹងជម្ងឺ COVID-19 និង

ជៀសវាងព័ត៌មានមិនពិត។ លោកអ្នកក៏អាចតាមដានព័ត៌មានថ្មីៗ ព័ត៌មានជំនួយ និងសេចក្តីជូនដំណឹងនានានៅលើទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ទីក្រុងរួមមាន @LongBeachCity និង @LBHealthDept និងតាមដានដោយប្រើសញ្ញា #COVID19LongBeach នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗ។

# # #